# ថ្នាំវ៉ាក់សាំង Hib

## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

(*បាក់តេរីបង្ក ជំងឺរលាកស្រោមខួរ ប្រភេទ* b)

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

*ជំងឺរលាកស្រោមខួរ* ប្រភេទ b (Hib) គឺជាជំងឺធ្ងន់ធ្ងរ ដែលបង្កឡើងដោយបាក់តេរី។ ជាធម្មតា ជំងឺនេះកើតឡើងចំពោះកុមារអាយុក្រោម 5 ឆ្នាំ។ ជំងឺនេះក៏អាចកើតឡើងចំពោះមនុស្សពេញវ័យ ដែលមានបញ្ហាវេជ្ជសាស្រ្តមួយចំនួនផងដែរ។

កូនរបស់លោកអ្នកអាចឆ្លងជំងឺរលាកស្រោមខួរបានដោយសារនៅជិតកុមារដទៃ ឬមនុស្សពេញវ័យ ដែលអាចមានបាក់តេរីបង្កជំងឺនេះ និងដែលមិនបានដឹងពីបាក់តេរីនេះ។ មេរោគឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ប្រសិនបើមេរោគនៅតែក្នុងច្រមុះ និងបំពង់ករបស់កុមារ កុមារនោះនឹងមិនកើតជំងឺនេះឡើយ។ ប៉ុន្តែពេលខ្លះ មេរោគចូលទៅក្នុងសួត ឬឈាម ហើយបន្ទាប់មក ជំងឺ Hib អាចបង្កបញ្ហាធ្ងន់ធ្ងរជាច្រើន។ នេះត្រូវបានគេហៅថា ជំងឺ Hib ធ្ងន់ធ្ងរ។

មុនពេលមានថ្នាំវ៉ាក់សាំង Hib ជំងឺ Hib គឺជាមូលហេតុនាំមុខ ដែលបង្កជំងឺរលាកស្រោមខួរដោយសារបាក់តេរីក្នុងចំណោមកុមារ អាយុក្រោម 5 ឆ្នាំ នៅសហរដ្ឋអាមេរិក។ ជំងឺរលាកស្រោមខួរ គឺជាការឆ្លងមេរោគលើស្រោមខួរក្បាល និងឆ្អឹងខ្នង។ ជំងឺនេះអាចបណ្តាលឲ្យខូចខួរក្បាល និងថ្លង់។ ជំងឺ Hib ក៏អាចបង្ក៖

- ជំងឺរលាកសួត
- អាការៈហើមបំពង់កធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យពិបាកដកដង្ហើម
- ការឆ្លងមេរោគក្នុងឈាម នៅសន្លាក់ ឆ្អឹង និងគម្របបេះដូង
- ការស្លាប់បាត់បង់ជីវិត

មុនពេលមានថ្នាំវ៉ាក់សាំង Hib កុមារប្រហែល 20,000 នាក់ នៅសហរដ្ឋអាមេរិក អាយុក្រោម 5 ឆ្នាំ កើតជំងឺ Hib នេះ ក្នុងមួយឆ្នាំៗ ហើយពួកគេប្រហែល 3% - 6% បានស្លាប់បាត់បង់ជីវិត។

ថ្នាំវ៉ាក់សាំង Hib អាចបង្ការជំងឺ Hib បាន។ ចាប់តាំងពីចាប់ផ្តើមប្រើប្រាស់ថ្នាំវ៉ាក់សាំង Hib ចំនួនករណីកើតជំងឺ Hib ធ្ងន់ធ្ងរ បានថយចុះចំនួនជាង 99%។ កុមារជាច្រើនថែមទៀតនឹងកើតជំងឺ Hib នេះ ប្រសិនបើយើងឈប់ផ្តល់ថ្នាំវ៉ាក់សាំង។

## 2 ថ្នាំវ៉ាក់សាំង Hib

មានថ្នាំវ៉ាក់សាំង Hib ជាច្រើនប្រភេទ។ កូនរបស់លោកអ្នកនឹងទទួលបានថ្នាំវ៉ាក់សាំងនេះចំនួន 3 ដូស ឬ 4 ដូស ផ្អែកលើប្រភេទថ្នាំវ៉ាក់សាំង ដែលបានប្រើប្រាស់។

ជាធម្មតា ចំនួនដូសនៃថ្នាំវ៉ាក់សាំង Hib ត្រូវបានណែនាំឲ្យចាក់ ក្នុងវ័យទាំងនេះ ដូចខាងក្រោម៖

- ដូសទីមួយ៖ អាយុ 2 ខែ
- ដូសទីពីរ៖ អាយុ 4 ខែ
- ដូសទីបី៖ អាយុ 6 ខែ (បើចាំបាច់ ផ្អែកលើប្រភេទនៃថ្នាំវ៉ាក់សាំង)
- ដូសចុងក្រោយ/រំឭក៖ អាយុ 12 - 15 ខែ

ថ្នាំវ៉ាក់សាំងមេរោគ Hib អាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

ថ្នាំវ៉ាក់សាំង Hib អាចចាក់ឲ្យ ជាផ្នែកមួយនៃថ្នាំវ៉ាក់សាំងរួមផ្សំ។ ថ្នាំវ៉ាក់សាំងរួមផ្សំ ត្រូវបានផលិតឡើង នៅពេលថ្នាំវ៉ាក់សាំងពីរ ឬច្រើនប្រភេទ ត្រូវបានបញ្ចូលគ្នាជាថ្នាំតែមួយ ដូច្នេះ ថ្នាំវ៉ាក់សាំងមួយអាចការពារជំងឺលើសពីរមួយ។

ជាធម្មតា កុមារអាយុលើសពី 5 ឆ្នាំ និងមនុស្សពេញវ័យ មិនត្រូវការថ្នាំវ៉ាក់សាំង Hib ទេ។ ប៉ុន្តែ ថ្នាំវ៉ាក់សាំងនេះអាចត្រូវបានណែនាំចំពោះកុមារអាយុច្រើនជាងនេះ ឬមនុស្សពេញវ័យ ដែលមានបញ្ហាលំពែងដំណើរការខុសធម្មតា ឬជំងឺកោសិកាឈាមរាងកណ្តៀវ មុនពេលវះកាត់យកលំពែងចេញ ឬបន្ទាប់ពីការវះកាត់ប្តូរសរីរាង្គខួរឆ្អឹង។ ថ្នាំវ៉ាក់សាំងនេះក៏អាចត្រូវបានណែនាំចំពោះមនុស្សអាយុ 5 ដល់ 18 ឆ្នាំ ដែលផ្ទុកមេរោគអេដស៍ផងដែរ។ សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកសម្រាប់ព័ត៌មានលម្អិត។

វេជ្ជបណ្ឌិតរបស់លោកអ្នក ឬបុគ្គល ដែលផ្តល់ថ្នាំវ៉ាក់សាំងដល់លោកអ្នក អាចផ្តល់ព័ត៌មានបន្ថែមទៀតដល់លោកអ្នកបាន។

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាំវ៉ាក់សាំងនេះ។

ថ្នាំវ៉ាក់សាំង Hib មិនគួរចាក់ឲ្យកុមារអាយុក្រោយ 6 សប្តាហ៍ឡើយ។

ជនណាដែលមានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិត បន្ទាប់ពីបានទទួលថ្នាំវ៉ាក់សាំង Hib ដូសមុន ឬមានប្រតិកម្មអាឡាក់ស៊ីចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំងនេះ មិនគួរទទួលថ្នាំវ៉ាក់សាំង Hib ឡើយ។ *សូមប្រាប់អ្នកផ្តល់ថ្នាំវ៉ាក់សាំង អំពីប្រតិកម្មអាឡាក់ស៊ី។*

អ្នកដែលមានជំងឺស្រាល អាចទទួលថ្នាំវ៉ាក់សាំង Hib បាន។ អ្នកដែលមានជំងឺមធ្យម ឬធ្ងន់ធ្ងរ គួររង់ចាំរហូតទាល់តែពួកគេជាសះស្បើយវិញ។ សូមពិភាក្សាជាមួយនឹងអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើអ្នកដែលទទួលថ្នាំវ៉ាក់សាំង មិនមានសុខភាពល្អនៅថ្ងៃដែលគ្រោងចាក់ថ្នាំវ៉ាក់សាំង។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលវិបាក អាចកើតមាន។ ជាធម្មតា ផលវិបាកទាំងនេះ មានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង។ ប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ ប៉ុន្តែប្រតិកម្មទាំងនេះកម្រនឹងកើតឡើង។

មនុស្សភាគច្រើន ដែលទទួលថ្នាំវ៉ាក់សាំង Hib ពុំមានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងទេ។

**បញ្ហាស្រាល** បន្ទាប់ពីចាក់ថ្នាំបង្ការ Hib៖
- បញ្ហាឡើងក្រហម ក្តៅ ឬហើម នៅកន្លែងចាក់ថ្នាំវ៉ាក់សាំង
- គ្រុនក្តៅ

បញ្ហាទាំងនេះ មិនមែនជាបញ្ហាធម្មតាទេ។ ប្រសិនបើបញ្ហាទាំងនេះកើតឡើង ជាធម្មតា បញ្ហាទាំងនេះចាប់ផ្តើមកើតឡើងភ្លាមៗ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង ហើយបន្តកើតឡើងសម្រាប់រយៈពេល 2 ឬ 3 ថ្ងៃ។

**បញ្ហាដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង៖**
ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើងក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

កុមារអាយុច្រើនជាងនេះ ក្មេងជំទង់ និងមនុស្សពេញវ័យ ក៏អាចជួបបញ្ហាទាំងនេះផងដែរ បន្ទាប់ពីទទួលថ្នាក់វ៉ាក់សាំងណាក៏ដោយ៖
- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទី បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុវិញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនអាចឈឺចុកចាប់ខ្លាំងត្រង់ស្មា ហើយពិបាកកម្រើកដៃ ដែលចាក់ថ្នាំវ៉ាក់សាំង។ ករណីនេះកម្រកើតឡើងណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**
- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពី**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួលហើមមុខ និងបំពង់ក ពិបាកដកដង្ហើមចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ ជាធម្មតា បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**
- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- ក្រោយមក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅគេហទំព័រ VICP នៅ **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់ សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅគេហទំព័រ CDC នៅ **www.cdc.gov/vaccines**

---

Vaccine Information Statement

# Hib Vaccine

4/02/2015 **Khmer**

42 U.S.C. § 300aa-26

Office Use Only

DCH-0449CA AUTH: P. H. S., Act 42, Sect. 2126.
Translation provided by the Immunization Action Coalition